# ពិធីមើលគ្រោះល្អ ឬអាក្រក់តាមក្បួនអាជានេយ្យ




ជាដំបូងយកអាយុអ្នកមើលមកតាំង ហើយយក៧ទៅសង បានសេសប៉ុន្មាន ចូរពិចារណាដូចខាងក្រោមនេះ :

សេស ១ ត្រូវត្រង់កំប៉ោយអាជានេយ្យ ទំនាយថា បើនឹងធ្វើដំណើរជួយប្រែទៅឆ្ងាយ នឹងបានរបស់ទ្រព្យគាប់ប្រសើរ ឬត្រូវបានលាភជាសត្វជើងពីរ ឬជើងបួន ។

បើសេស ២ ត្រូវត្រង់បបូរមាត់អាជានេយ្យ ទំនាយថានឹងបានទទួលលាភផល ជារបស់ស៊ីចុកយ៉ាងច្រើនសន្ធឹកសន្ធាប់ តែគួរប្រយ័ត្នពាក្យសម្តី ក្រែងនាំឱ្យមានទុក្ខទោសដល់ខ្លួន ។

បើសេស ៣ ទំនាយថានឹងបានជាទីទុកចិត្ត ស្និទ្ធស្នាលពីអ្នកធំ មានគេផ្គុងផ្គើមដោយសេចក្តី មេត្តាករុណា ។

បើសេស ៤ ត្រូវត្រង់ជើងមុខអាជានេយ្យ ទំនាយនឹងត្រូវផ្លាស់ប្តូរទីកន្លែង មានការហត់នឿយយ៉ាងខ្លាំក្នុងការប្រកបមុខរបររកស៊ី លាភសក្ការៈបានមកជាបង្គួរ ។

បើសេស ៥ ត្រូវត្រង់កន្ទុយអាជានេយ្យ ទំនាយថានឹងមានសេចក្តីក្តៅក្រហាយ នឿយណាយ ក្នុងចិត្តធ្លោយគំនិតដោយការជួយយកអាសារគេ នាំឱ្យខាតបង់លាភសក្ការៈផ្ទាល់ខ្លួន បើពុំនោះនឹងមានសេចក្តីមន្ទិលសង្ស័យអំពីមនុស្សដែលធ្លាប់ជាទីទំនុកទុកចិត្ត ។

បើសេស ៦ ត្រូវត្រង់លិង្គអាជានេយ្យ ទំនាយថានឹងត្រូវដល់គូររួមមិត្តមេត្រីស្នេហានឹងភេទ ផ្សេងគ្នា តែគួរកុំសេពគប់ និងឱ្យមនុស្សស្នាក់អាស្រ័យនាំឱ្យមានទុក្ខទោសទៅថ្ងៃក្រោយ ។
បើសេស ៧ ត្រូវត្រង់ជើងក្រោយអាជានេយ្យ ទំនាយថា នឹងមានសត្រូវប៉ុនប៉ងប្រទូស្តរាយជា ច្រើន គួរកុំធ្វើដំណើរទៅកាន់ទីឆ្ងាយ ព្រោះនាំឱ្យមានទុក្ខទោសដល់ខ្លួន ។